# ឯកសារពិស្តារ

## ម៉ូឌុល ១

# អភិបាលកិច្ចល្អ



# ម៉ូឌុលទី១ ៖ ការស្វែងយល់អំពីអភិបាលកិច្ចល្អ

## ក) ទិសដៅ ៖

សិក្ខាកាមនឹងអាចៈ

- យល់ពីការអនុវត្តន៍ដើម្បីឱ្យមានអភិបាលកិច្ចល្អ តាមរយៈគម្រោងផ្សេងៗនៅកម្ពុជា
- កំណត់បានពីលក្ខណៈនៃសង្គមល្អ និងតួនាទីរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ក្នុងការកសាងសង្គមល្អ
- យល់ដឹងអំពីទស្សនទាននៃ អភិបាលកិច្ច និងអភិបាលកិច្ចល្អ
- ឆ្លុះបញ្ចាំងពីការអនុវត្តគម្រោងអភិបាលកិច្ចល្អនៅកម្ពុជា ទៅនឹងទស្សនទានទូទៅរបស់អភិបាលកិច្ចល្អ។

## ខ) មាតិកា ៖

### ១. ការណែនាំអំពីអភិបាលកិច្ចល្អ

### ២. សង្គមល្អ

២.១. ទស្សនទានសង្គមល្អ

២.២. តួនាទីប្រជាពលរដ្ឋ និងរដ្ឋាភិបាល

### ៣. ការយល់ដឹងពីទស្សនទាននៃអភិបាលកិច្ចល្អ

៣.១. និយមន័យអភិបាលកិច្ច និងអភិបាលកិច្ចល្អ

៣.២. គោលការណ៍អភិបាលកិច្ចល្អ

៣.៣. ចរិតលក្ខណៈរបស់អភិបាលកិច្ចល្អ

៣.៤. អភិបាលកិច្ចថ្នាក់ក្រោមជាតិ

៣.៥. ទស្សនៈទៅលើវិមជ្ឈការ

### ៤. ក្របខ័ណ្ឌគោលនយោបាយអភិបាលកិច្ចនៅកម្ពុជា

៤.១. គោលការណ៍អភិបាលកិច្ចនៅកម្ពុជា

៤.២. គោលដៅអភិវឌ្ឍសហស្សវត្ស

៤.៣. រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ

## ១. សេចក្តីផ្តើម:

ជាប្រវត្តិសាស្ត្រ ពិសេសបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ គេបានចាត់ទុកការងារគ្រប់គ្រងរដ្ឋក្នុងប្រទេសមួយ ជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ ក្របខ័ណ្ឌនយោបាយប្រជាធិបតេយ្យរបស់រដ្ឋាភិបាល បានស្នើសុំឱ្យមានមុខងារឯករាជ្យ ៣យ៉ាងដែលមានការទាក់ទងគ្នាទៅវិញទៅមកគឺ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ។ ក្នុងសង្គមខុសៗគ្នារយៈពេល ៥០ ឆ្នាំកន្លងមកនេះ មុខងារទាំងនេះត្រូវបានរៀបចំផ្សេងៗគ្នា តែនៅរក្សាគោលបំណងរួម។

ដោយមានការកើនឡើងនូវការបាត់ការទុកចិត្តពីប្រជាជនសាមញ្ញ ទៅលើស្ថាប័នរដ្ឋាភិបាល ។ ការមិនពេញចិត្តនេះមកពីកត្តាជាច្រើនដូចជា សមត្ថភាពរបស់ស្ថាប័នក្នុងការឆ្លើយតបចំពោះផលប្រយោជន៍ និងការរំពឹងទុករបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះ ភាពចន្លោះប្រហោងនៃគោលនយោបាយរបស់រដ្ឋាភិបាល និងការអនុវត្តកាន់តែរីកធំឡើង ស្របគ្នានឹងការកើនឡើងនូវគម្លាតរវាងអ្នកក្រ និងប្រជាជនដែលគេមិនអើពើ ពីស្ថាប័នរដ្ឋាភិបាល ភាពក្រីក្រដែលរកទីបញ្ចប់គ្មាន និងដោយ មានការកើនឡើងនូវសារៈសំខាន់នៃផលប្រយោជន៍ ជំនួញឯកជនក្នុងប្រទេសនិងអន្តរជាតិ ។ ជាលទ្ធផលគោល គំនិតនៃការគ្រប់គ្រង ឥឡូវនេះបានចាប់ផ្តើមប្តូរទៅជាទ្រឹស្តីអភិបាលកិច្ចវិញ។ ក្នុងនិយមន័យងាយយល់ អភិបាលកិច្ចមានន័យស្មើ នឹងមុខងាររបស់រដ្ឋ ហើយដូចនេះអភិបាលកិច្ចល្អ គឺស្មើនឹងមុខងារដ៏មានប្រសិទ្ធភាពរបស់រដ្ឋ និងស្ថាប័នរបស់ខ្លួន ដែលលើកស្ទួយសមធម៌ និងយុត្តិធម៌សង្គម ។

ធនាគារពិភពលោក គឺជាអ្នកនាំយកទស្សនៈអំពី "អភិបាលកិច្ចល្អ" ចូលទៅក្នុងកិច្ចការអភិវឌ្ឍន៍មុនគេក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ។ បទពិសោធន៍របស់ធនាគារ ចំពោះភាពបរាជ័យនៃគោលនយោបាយសេដ្ឋកិច្ចក្នុងបណ្តាប្រទេសអាហ្វ្រិក ធ្វើឱ្យធនាគារទម្លាក់ការបរាជ័យនេះទៅលើ "អភិបាលកិច្ចមិនល្អ" មានដូចជា អប្រសិទ្ធផលខាងផ្នែករដ្ឋបាល អំពើពុករលួយ ការខ្វះតម្លាភាព...។ល។ ក្នុងប្រទេសទាំងនេះ ។ ការបង្កើតចេញ ជាគោលគំនិតអំពីអភិបាលកិច្ចមិនល្អ បាននាំឱ្យមានការរៀបចំគោលគំនិតអំពីអភិបាលកិច្ចល្អ ដែលដាក់បញ្ចូល វិស័យជាច្រើន ដូចជាប្រសិទ្ធផលខាងផ្នែករដ្ឋបាល នីតិរដ្ឋ គណនេយ្យភាព និងតម្លាភាព ។ ទោះជាយ៉ាងណា ក៏ដោយធនាគារពិភពលោក មិនបានដាក់ អភិបាលកិច្ចល្អ" ឱ្យពាក់ព័ន្ធជាមួយនឹងរបបនយោបាយជាក់លាក់ណាមួយទេ ។ ការពាក់ព័ន្ធរវាង " អភិបាលកិច្ចល្អ " និងលទ្ធិប្រជាធិបតេយ្យ ត្រូវបានជំរុញ ឱ្យចូលទៅក្នុងការងារ អភិវឌ្ឍន៍ តាមរយៈភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ដែលលើកកំពស់ លទ្ធិប្រជាធិបតេយ្យដោយបង្កើតនូវលក្ខខណ្ឌជំនួយ ដើម្បីលើកកំពស់ការបោះឆ្នោតជាទៀងទាត់ សិទ្ធិមនុស្ស និងនីតិរដ្ឋ។

UNDP ចាត់ទុកអភិបាលកិច្ចល្អ ថាជាអត្តិភាពនៃបណ្តាញរបស់ស្ថាប័នរដ្ឋាភិបាល រួមជាមួយច្បាប់ និងបទបញ្ញត្តិ ក្នុងការរួមគ្នាបង្កើត និងរក្សានូវបរិស្ថានសង្គមដែលជាមូលដ្ឋាននៃការអភិវឌ្ឍរបស់មនុស្ស និងសម្រាប់

ក្រុមទាំងអស់នៅក្នុងសង្គម ។ ដូច្នេះអភិបាលកិច្ចល្អ គឺជាសំណុំរឿងមួយរបស់អភិបាលកិច្ច ដែលធនធានសាធារណៈ និងបញ្ហាផ្សេងៗត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ប្រសិទ្ធផល និងឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម ។ ដូច្នេះការចូលរួមជាសាធារណៈ ដាក់ឥទ្ធិពលលើការសម្រេចចិត្ត តម្លាភាព និង គណនេយ្យភាព គឺជាចំណុចធំៗ/សញ្ញាសម្គាល់នៃអភិបាលកិច្ចល្អ (UNDP ឆ្នាំ ១៩៩៧) ។

## ២ សង្គមល្អ

### ២.១ ទស្សនទានសង្គមល្អ

| តម្រូវការជាមូលដ្ឋាន | ការចូលរួម | ការចងក្រងគ្នា |
|---|---|---|
| • សន្តិសុខខាងសេដ្ឋកិច្ច<br>• សេវាសង្គមល្អ<br>• សុវត្ថិភាពរូបវន្តនិងសន្តិភាព | • អភិបាលកិច្ចដែលមានការឆ្លើយតប និងរាប់បញ្ចូល<br>• សិទ្ធិស្មើគ្នា និងយុត្តិធម៌ | • គោរពវប្បធម៌ និងមរតកដូនតា<br>• យកចិត្តទុកដាក់ និងចែក រំលែក |

*ប្រភព :Participatory Research in Asia & the World Bank, "Understanding Governance", November 2008, 2nd Social Accountability School (SAS 2)*

➢ **តម្រូវការមូលដ្ឋាន (Basic Needs)**

តម្រូវការជាអាទិភាពសម្រាប់ទ្រទ្រង់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ទាំងសន្តិសុខ និងសុវត្ថិភាព ត្រូវបាន បំពេញទាន់ពេលវេលា និងធានាឱ្យមាន :

- សន្តិសុខខាងសេដ្ឋកិច្ច - ប្រជាពលរដ្ឋទូទៅ មានជីវភាពសមរម្យ រួចចាកផុតពីភាពអត់ឃ្លាន និងបន្ទាត់នៃភាពក្រីក្រ
- សេវាសង្គមល្អ - សេវាសាធារណៈ (ដូចជាការព្យាបាលសុខភាព បង្រៀន ...) មានគុណភាព និងបើកចំហសម្រាប់ប្រជាពលរដ្ឋគ្រប់រូប មានលទ្ធភាពទទួលបានប្រកបដោយសមធម៌
- សុវត្ថិភាពរូបវន្តនិងមានសន្តិភាព - ប្រជាពលរដ្ឋទូទៅរស់នៅមានសុវត្ថិភាព ចាកផុតអំពើនានាដែលបង្ក ឱ្យមានគ្រោះថ្នាក់ចំពោះខ្លួន និងចេះសាមគ្គីគ្នា ។

➢ **ការចូលរួម (Participation)**

ប្រជាពលរដ្ឋធ្វើជាម្ចាស់ប្រទេសពិតប្រាកដ និងចាត់ចែងវាសនារបស់ខ្លួនដោយខ្លួនឯង ដែលរួមមាន :

- អភិបាលកិច្ចដែលមានការឆ្លើយតប និងរាប់បញ្ចូល - អភិបាលកិច្ចជាភារកិច្ចរួម និងត្រូវចូលរួមដោយរដ្ឋ ទីផ្សារ និងប្រជាពលរដ្ឋ (ឬសង្គមស៊ីវិល) និងធានាមិនបោះបង់ចោលសមាជិកសង្គមណាម្នាក់ទោះបីមានការខុសគ្នាខាងពូជសាសន៍ ជំនឿសាសនា អាយុ ពណ៌សម្បុរ ភេទ និន្នាការនយោបាយ ។
- សិទ្ធិស្មើគ្នា និងយុត្តិធម៌ -ប្រជាពលរដ្ឋទូទៅរស់នៅមានសិទ្ធិស្មើគ្នា ចូលរួមក្នុងដំណើរការសំរេចចិត្ត និងទទួលផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌ ។

➤ **ការចងក្រងគ្នា(Association)**

ប្រជាពលរដ្ឋរស់នៅប្រៀបដូចជាក្រុមតែមួយ ដែលប្រកាន់ខ្ជាប់នូវ:

- ការគោរពវប្បធម៌ និងមរតកដូនតា -គោរពនិងថែរក្សាការពារសមិទ្ធិផលនានានៅក្នុងប្រទេស
- ការយកចិត្តទុកដាក់ និងចែករំលែក -គាំទ្រ និងជួយគ្នាទៅវិញទៅមកដោយមិនប្រកាន់ឬរើសអើង

| **តួនាទីប្រជាពលរដ្ឋ** | | | | **តួនាទីរដ្ឋាភិបាល** |
|---|---|---|---|---|
| - ប្រជាពលរដ្ឋសកម្ម និងរួមដៃការងារ<br>- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ | ⇨ | **ការចូលរួម** | ⇦ | - ជាអ្នកសម្របសម្រួល |
| - ប្រជាពលរដ្ឋសកម្ម និងរួមដៃការងារ<br>- សាមគ្គីភាពរបស់ប្រជាពលរដ្ឋ<br>- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ | ⇨ | **ការចងក្រងគ្នា** | ⇦ | - ជាអ្នកសម្របសម្រួល<br>- ជាអ្នកជម្រុញ |
| - សាមគ្គីភាពរបស់ប្រជាពលរដ្ឋ<br>- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ | ⇨ | **តម្រូវការចូលផ្ទាន** | ⇦ | -ជាអ្នកសម្របសម្រួល(ខ្លះ)<br>- ជាអ្នកជម្រុញ<br>- ជាអ្នកផ្តល់ឱ្យ |

*ប្រភព :Participatory Research in Asia & the World Bank, "Understanding Governance", November 2008, 2nd Social Accountability School (SAS 2)*

## ២.២តួនាទីរបស់ប្រជាពលរដ្ឋនិងរដ្ឋាភិបាល

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ

១.តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិ និងតួនាទីអ្វីខ្លះ?

២.តើរដ្ឋមានតួនាទីអ្វីខ្លះ?

យោងតាមជំពូកទី៣ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា អំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ:

| តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះ? | មាត្រា |
|---|---|
| ការគោរពសិទ្ធិមនុស្ស | ៣១ |
| សិទ្ធិរស់រានមានជីវិត សេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន | ៣២ |
| សិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត | ៣៤ |
| សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ | ៣៥ |
| សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី | ៣៧ |
| ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូរបស់ប្រជាពលរដ្ឋ ។ | ៣៨ |
| សិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ាឬប្ដឹងទារសំណងជួសជុលការខូចខាតដែលបណ្ដាលមកពី អំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ | ៣៩ |
| សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សារព័ត៌មាន បោះពុម្ពផ្សាយការប្រជុំ | ៤១ |
| សិទ្ធិបង្កើតសមាគម | ៤២ |
| ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់ចោល | ៤៥ |
| ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ | ៤៩ |

យោងតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា:

- ជំពូកទី៤ ស្ដីពី : **របបនយោបាយ**
- ជំពូកទី៥ ស្ដីពី : **សេដ្ឋកិច្ច**
- ជំពូកទី៦ ស្ដីពី : **អប់រំ វប្បធម៌ និងសង្គមកិច្ច**

| តើរដ្ឋមានតួនាទីអ្វីខ្លះ? | មាត្រា |
|---|---|
| **ជំពូកទី៤ : អំពីរបបនយោបាយ** | |
| • រក្សាការពារឯករាជ្យអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ការពារឯកភាពជាតិ ។<br>• រក្សាការពារទំនៀមទម្លាប់ នឹងប្រពៃណីល្អរបស់ជាតិ ។<br>• ការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ | ៥២ថ្មី |

| | |
|---|---|
| • យកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។ | |
| **ជំពូកទី៥: អំពីសេដ្ឋកិច្ច** | |
| រក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ | ៥៩ |
| យកចិត្តទុកដាក់ ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។ | ៦២ |
| **ជំពូកទី៦ : អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច** | |
| • ការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត ។<br>• យកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ | ៦៥ |
| សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ ។ ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យរោគដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។ | ៧២ |
| រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើន ក្នុងបន្ទុកហើយឥតទីពឹង ។ | ៧៣ |

## យោងតាម**ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល**
## **រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ជំពូកទី១ ស្តីពី : **បទបញ្ញត្តិទូទៅ**

ជំពូកទី ២ ស្តីពី : **ក្រុមប្រឹក្សា**

| **តើក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានតួនាទីអ្វីខ្លះ?** | **មាត្រា** |
|---|---|
| **ជំពូកទី១ ស្តីពី : បទប្បញ្ញត្តិទូទៅ** | |
| ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រួមមាន:<br>• ភាពជាតំណាងសាធារណៈ<br>• ស្វ័យភាពរបស់មូលដ្ឋាន<br>• ការពិគ្រោះយោបល់ និងការចូលរួម<br>• ការឆ្លើយតប និងគណនេយ្យភាព<br>• ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន<br>• ការលើកស្ទួយសមធម៌<br>• តម្លាភាព និងសុចរិតភាព | ១២ |

| | |
|---|---|
| • វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។ | |
| **ជំពូកទី២ ស្តីពី : ក្រុមប្រឹក្សា**<br>**ផ្នែកទី២ : តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា** | |
| ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ:<br>• ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>• ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>• ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល<br>• អ្នកពាក់ព័ន្ធនានា ។ | ៣៨ |
| ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។ | ៤៣ |
| ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬអ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រដ្ឋ ឬក្នុងក្រុមប្រឹក្សាណាមួយ ឬជនណាម្នាក់ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា:<br>• ការប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញ ដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈណាមួយ<br>• ការមិនបានប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀត ដែលស្ថិតនៅក្រោមអំណាច ឬការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធាន សាធារណៈ ។ | ៤៨ |
| ការរំលោភអំណាចរួមមានសកម្មភាពដូចខាងក្រោម :<br>• ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់ ។<br>• ការកាន់កាប់ ឬការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិ មកធ្វើជារបស់ខ្លួនដោយខុសច្បាប់<br>• ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ<br>• ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ<br>• ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលចំណាយ ឬ រង្វាន់នោះមិនបានកំណត់នៅក្នុងច្បាប់<br>• ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រិត្យ ឬ អនុក្រឹត្យ ឬ ប្រកាស<br>• ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា<br>• ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍គ្រួសាររបស់ខ្លួន ។ | ៤៩ |

## ៣. ទស្សនទាននៃអភិបាលកិច្ចល្អ

### ៣.១ និយមន័យ

"**អភិបាលកិច្ច** គឺជាការប្រើប្រាស់នូវសិទ្ធិអំណាចនយោបាយ, សេដ្ឋកិច្ច និងរដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការ របស់ជាតិមួយ ។ វាគឺជាយន្តការ, ដំណើរការ និង ច្បាប់សាំញ៉ាំ ដែលតាមរយៈនេះ ប្រជាពលរដ្ឋ និងក្រុមផ្សេងៗ បញ្ជាក់ពីផលប្រយោជន៍របស់ខ្លួន, ប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន, និង សម្រុះសម្រួលភាពខ្វែងគំនិតដែល គេមាន ។ (UNDP)

**អភិបាលកិច្ច**

អភិបាលកិច្ច គឺជា "..ច្បាប់ទម្លាប់ និងច្បាប់សំខាន់ៗដែលរដ្ឋអំណាចនៅក្នុង ប្រទេសមួយ បានប្រើ ដើម្បីផលប្រយោជន៍រួម ។ នេះរួមមាន : (១) ដំណើរការនៃរដ្ឋអំណាចត្រូវបានជ្រើសរើស,តាមដាន និងជំនួស នូវច្បាប់ ទាំងនោះ (២) សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវ ធនធានរបស់ខ្លួន និងអនុវត្តតាម គោលនយោបាយ និង (៣) ការគោរពរបស់ប្រជាពលរដ្ឋ និងរដ្ឋ ចំពោះច្បាប់ស្ថាប័នដែលគ្រប់គ្រងអន្តរកម្មផ្នែកសេដ្ឋកិច្ច និងសង្គម ។" **(ធនាគារពិភពលោក)**

"**អភិបាលកិច្ច**" គឺជាសកម្មភាព ជាដំណើរការ ជារបៀបនៃការដឹកនាំ គ្រប់គ្រង ចាត់ចែង ឬ បីបាច់ថែរក្សា និងជាការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ ។ **អភិបាលកិច្ចល្អ** គឺជាសកម្មភាព ជាដំណើរការ ជារបៀបនៃការដឹកនាំ គ្រប់គ្រង ចាត់ចែង ឬ បីបាច់ថែរក្សា និងជាការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តី សម្រេចចិត្តនោះ ដែលប្រកាន់ភ្ជាប់នូវគោលការណ៍ ៨រួមមាន: ១) ការចូលរួម ២) ការឆ្លើយតប ៣) គណនេយ្យភាព ៤) ការព្រមព្រៀង ៥) ការតម្លាភាព ៦) សមភាព និងគ្រប់សមាជិកនៃសង្គម ៧) ប្រសិទ្ធភាព-ប្រសិទ្ធផល ៨) គោលការណ៍ច្បាប់-នីតិរដ្ឋ (គម្រោង*អភិបាលកិច្ចល្អមូលដ្ឋាននៃក្រសួងមហាផ្ទៃ*)

**អភិបាលកិច្ចល្អ** មានន័យថា មានសមត្ថភាពគ្រប់គ្រងកិច្ចការ និងធនធានរបស់ប្រទេសជាតិ ប្រកបដោយឆន្ទៈ មានលក្ខណៈបើកចំហ តម្លាភាព គណនេយ្យភាព សមធម៌ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ។ (UNDP).

## ៣.២ គោលការណ៍អភិបាលកិច្ចល្អ

ក. អភិបាលកិច្ចល្អគឺផ្តោតលើគោលបំណងរបស់អង្គភាព និងលទ្ធផលសំរាប់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវាកម្ម។

ខ. អភិបាលកិច្ចល្អគឺជាការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានការកំណត់នូវមុខងារ និងតួនាទី ច្បាស់លាស់។

គ. អភិបាលកិច្ចល្អគឺជាការលើកស្ទួយគុណតម្លៃរបស់អង្គភាពទាំងមូល និងបង្ហាញពីគុណតម្លៃរបស់អភិបាលកិច្ចល្អ តាមរយៈការប្រព្រឹត្ត។

ឃ.អភិបាលកិច្ចល្អគឺជាការផ្តល់នូវការជូនដំណឹង ការសំរេចចិត្ត និងការគ្រប់គ្រងហានិភ័យប្រកបដោយតម្លាភាព។

ង. អភិបាលកិច្ចល្អ គឺជាការបង្កើនសមត្ថភាព និងលទ្ធភាពរបស់អង្គភាពគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

ច. អភិបាលកិច្ចល្អ គឺជាការគៀងគរអ្នកពាក់ពន្ធ័នានា និងធ្វើឱ្យមានគណនេយ្យភាពពិតប្រាកដ។

## ៣.៣ ចរិតលក្ខណៈរបស់អភិបាលកិច្ចល្អ

### *ក. ការចូលរួម*

រដ្ឋាភិបាលជាកន្លែងដែលប្រើអភិបាលកិច្ចល្អជាក្បួនច្បាប់ ប្រជាពលរដ្ឋអាចចូលរួមយ៉ាងសកម្ម ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តដោយផ្ទាល់ ឬដោយប្រយោល តាមរយៈក្រុម ឬភ្នាក់ងារដែល តំណាងឱ្យផលប្រយោជន៍របស់គាត់។

### *ខ. និតិរដ្ឋ*

អភិបាលកិច្ចល្អជួយធ្វើឱ្យច្បាប់នានាជាពិសេសដែលពាក់ព័ន្ធសិទ្ធិមនុស្ស ត្រូវបានអនុវត្តបានប្រកបដោយយុត្តិធមិ និងមិនលំអៀង។

### *ឃ. តម្លាភាព*

តម្លាភាពត្រូវបានបង្កើតឡើងដោយការផ្តល់ពតិមានដោយសេរី។ ដំណើរការ ច្បាប់ និងពតិមានអាចផ្តល់ដោយផ្ទាល់ ដល់អ្នកដែលត្រូវការវា និងផ្តល់ពតិមានគ្រប់គ្រាន់ ដើម្បីស្វែងយល់ និងត្រួតពិនិត្យ តាមដាននូវពតិមានទាំងនោះ។

### *ង. ការឆ្លើយតប*

នៅក្នុងការអនុវត្តន៏អភិបាលកិច្ចល្អរបស់រដ្ឋាភិបាល បណ្ដាភ្នាក់ងារផ្ដល់សេវាបានទាន់ពេលវេលា និងឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ម្ចាស់ឆ្នោត។

ច. ***ការព្រមព្រៀង***

ចំណាប់អារម្មណ៏ និងមតិយោបល់មានភាពខុសគ្នាក្នុងគ្រប់សង្គមនិមួយៗ។ អភិបាលកិច្ចល្អខិតខំយ៉ាងខ្លាំងដើម្បីសម្រុះសម្រួលភាពខុសគ្នាទាំងនេះអោយក្លាយជាមតិទូទៅរួមមួយចំពោះអ្វីដែលល្អបំផុតដើម្បីសំរេចរាល់កិច្ចការទាំងអស់។

***ឆ. សមធម៌***

គ្រប់បុរសនិងស្ត្រី មិនប្រកាន់អាយុ យេនឌ័រ ឬស្ថានភាពនៅក្នុងជីវិតរស់នៅសុទ្ធតែមានឱកាសដើម្បីពង្រីក ឬ រក្សានូវភាព ក្សេមក្សាន្ដរបស់គេ។

***ជ. ប្រសិទ្ធភាព និងប្រសិទ្ធផល***

រដ្ឋាភិបាលដែលបាននឹងកំពុងអនុវត្តអភិបាលកិច្ចល្អ បង្កើតលទ្ធផលដែលសមស្របនិងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ដោយប្រើប្រាស់ធនធានបានយ៉ាងប្រសើរ។

***ឈ. គណនេយ្យភាព***

ក្នុងអភិបាលកិច្ចល្អ អ្នកធ្វើសេចក្ដីសំរេចចិត្តក្នុងរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិលអាចឆ្លើយទៅសាធារណ:ជនផង និងទៅស្ថាប័នពាក់ពន្ធ័នានាផង។

## ៣.៤. ឧបសគ្គនានានៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ

អភិបាលកិច្ចបែបប្រជាធិបតេយ្យសំដៅលើការគ្រប់គ្រងកិច្ចការក្នុងសង្គម ដោយផ្អែកលើគោលការណ៏ជាសកលរបស់លទ្ធិប្រជាធិបតេយ្យដែលជាប្រពន្ធ័ច្បាប់ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋមានការយល់ព្រម និងចូលរួមជាអតិបរមា ធ្វើឱ្យអ្នកគ្រប់គ្រងគោរពច្បាប់ និងមានគណនេយ្យភាព និងបន្ទាប់មកមានការឆ្លើយតបទៅនឹងផលប្រយោជន៏ និងតម្រូវការរបស់សាធារណជន ។ មូលដ្ឋានគ្រឹះ សំខាន់ៗបំផុត នៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺថាប្រទេសមួយត្រូវមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ត្រូវមានគណបក្សច្រើន ជាមួយការប្រកួតប្រជែងគ្នាដែលបានរៀបចំយ៉ាងល្អ និងសមហេតុសមផល ពណ៌នាឱ្យយល់ដឹង ការគោរពនិងការការពារសេរីភាពជនស៊ីវិល និងសិទ្ធិមនុស្សក្នុងសង្គម និងការជំរុញគាំទ្រ និងការចូលរួមសកម្មពីសង្គមស៊ីវិលដែលមានចំណាប់អារម្មណ៏ខ្លាំងក្លា។

មូលដ្ឋាននៃនិយមន័យដែលបានបញ្ជាក់ខាងលើអាចកំណត់បាននូវទិដ្ឋភាព ៣ ចំបងៗនៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ ។

**ទី មួយ:** អភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺជាលទ្ធផលចុងក្រោយ និងជាមធ្យោបាយ មួយឆ្ពោះទៅសំរេចលទ្ធលនោះផងដែរ ។ វាជាលទ្ធផលចុងក្រោយ ជាសីលធមិចាំបាច់មួយដែលស្របទៅនឹងការចង់ បានរបស់មនុស្សជាតិ រួមមាន សេរីភាព និងសង្គមដែលមានលំដាប់ថ្នាក់នយោបាយមួយ មានលក្ខណៈល្អប្រសើរពោរពេញទៅដោយ មនុស្សធមិ និងកាន់តែឈានជិតទៅដល់សមធមិ ( ភាពស្មើគ្នា) ។

**ទី ពី រ:** អភិបាលកិច្ចបែបប្រជាធិបតេយ្យមិនដែលល្អឥតខ្ចោះនោះទេព្រោះវាជាដំណើរការអនុវត្តនិងមិនមែនគ្រាន់តែជាលទ្ធផលចុងក្រោយនោះទេ ។ ទូទាំងពិភពលោក ដំណើរការដែលមានជាប្រចាំក្នុងការពង្រីកលំហនយោបាយដើម្បីធានាថាមនុស្សគ្រប់រូបមានភាពស្មើគ្នា ក្នុងការទទួលបានសិទ្ធិជាមូលដ្ឋាន និងសេរីភាព ។ ប្រទេសក្រិចពីបុរាណ មិនចាត់ទុកទាសករ និងស្ត្រីថាជាប្រជាពលរដ្ឋនោះទេ ដោយពួកគេមិនអាចចូលរួមដំណើរនយោបាយបានទេ ។ នៅក្នុងសង្គមអាហ្វ្រិកបុរាណជាច្រើនទៀត ការសំរេចចិត្តផ្នែកនយោបាយ គឺទុកឱ្យតែបុរសចាស់ៗតែប៉ុណ្ណោះ ស្ត្រី និងក្មេងៗត្រូវបានផាត់ចេញ ។ បច្ចុប្បន្នមានប្រទេសជាច្រើននៅលើពិភពលោក ដែលជនជាតិភាគតិចត្រូវគេរើសអើងមិនបានទទួលសិទ្ធិជាប្រជាពលរដ្ឋពេញលេញ ទោះបីជាសិទ្ធិទាំងនោះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសគេក៏ដោយ ។ អ្នកក្រ និងអ្នកងាយរងគ្រោះមានមូលហេតុច្រើន ដែលគេមិនអាចអនុវត្តសិទ្ធិគេបានដោយពេញលេញ ។ នៅទូទាំងពិភពលោក ការគាំទ្រទៅលើអភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺជាការផ្តោតទៅលើការពង្រីកលំហរនយោបាយ ដើម្បីផ្តល់ឱ្យសំលេងរបស់ស្ត្រី អ្នកក្រីក្រ និងក្រុមដែលគេផាត់ចេញបានឮឡើងនូវគ្រប់បញ្ហាដែលគេជួបប្រទះ ។

**ទី ៣:** អភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺទម្រង់ការអនុវត្តន៍នយោបាយ ដែលផ្តោតលើទស្សនទានជាសកលនៃនិតិរដ្ឋ ការទទួលស្គាល់ពេញសិទ្ធិ ការចូលរួម គណនេយ្យភាពរបស់អ្នកដឹកនាំ ។ នៅពេលស្ថាប័នមានដំណើការល្អ និងមានយន្តការតំណាងឱ្យសហគមន៍ ទៅ ថ្នាក់ជាតិ អន្តរជាតិ អភិបាលកិច្ចបែបប្រជាធិបតេយ្យគួរពង្រីកឱ្យខ្លាំងក្លានូវយល់ព្រម និងចូលរួម ភាពពេញសិទ្ធិ និងគណនេយ្យភាព របស់អ្នកគ្រប់គ្រង និងការគ្រប់គ្រងនឹងនាំទៅឱ្យមានការល្អប្រសើរឡើង ក្នុងការគ្រប់គ្រងធនធាន ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវ ការតាមមូលដ្ឋាន និងការចង់បានរបស់ប្រជាពលរដ្ឋ ។ នៅក្នុងពេលនេះ អភិបាល កិច្ចបែបប្រជាធិបតេយ្យគឺ ត្រូវតែមើលជាមធ្យោបាយមូលដ្ឋាន ដែលឈានទៅដល់លទ្ធផលដទៃឯទៀត ដែលក្នុងនោះមានការអភិវឌ្ឍន៍ និងសន្តិសុខសង្គម ។

## តើមានទំនាក់ទំនងអ្វីរវាង អភិបាលកិច្ចបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ?

ដើម្បីដំណើរការអភិបាលកិច្ចល្អឱ្យមានចេរភាព ចាំបាច់ត្រូវអនុវត្តលទ្ធិប្រជាធិបតេយ្យ ។ គេមានភស្តុតាងដែលអាចបញ្ជាក់បានថាប្រពន្ធ័អភិបាលកិច្ចល្អទាល់តែមានប្រពន្ធ័ប្រជាធិបតេយ្យទៅជាមួយផង ។ ប្រជាធិបតេយ្យផ្តល់ឱកាសច្រើនសំរាប់ជាលំហដល់ប្រជាពលរដ្ឋ ដើម្បីឱ្យប្រជាពលរដ្ឋមានការចូលរួម និងសំរាប់ក្រុមឯករាជ្យមានការកកើតឡើង មានអ្នកនយោបាយប្រឆាំងអាចរៀបចំឡើង ហើយបុគ្គលម្នាក់ៗអាចអនុវត្ត យកបទពិសោធន៍ ក្នុងការជ្រើសរើសដោយសេរីនៅសង្គមដែលមានអភិបាលកិច្ចបែបប្រជាធិបតេយ្យ ។ មូលហេតុទាំងនេះហើយ ដែលនាំឱ្យ ប្រជាធិបតេយ្យក្លាយខ្លួនជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការប្រឹងប្រែង ដើម្បីឱ្យមានអភិបាលកិច្ចល្អក្នុងសង្គម ។

## ៣.៥ ទស្សនៈទាននៃអភិបាលកិច្ចមូលដ្ឋាន

### ក)_ អ្វីទៅជារដ្ឋបាលមូលដ្ឋាន?

រដ្ឋបាលមូលដ្ឋាន គឺជាពាក្យក្តោបមួយ ពាក្យនេះអាចមានន័យខុសគ្នានៅក្នុងតំបន់ផ្សេងៗក្នុងពិភពលោក ហេតុដូច្នេះ រដ្ឋបាលមូលដ្ឋាអាចមានន័យថា រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ស្រុកប្រតិបត្តិ ។ល។ ទោះបីជាមានភាពចំរុះយ៉ាងដូច្នេះក៏ដោយយើងត្រូវដឹងនូវប្រភេទពីរនៃរដ្ឋបាលមូលដ្ឋាន:

- រដ្ឋបាលមូលដ្ឋាន ដែលគ្រប់គ្រង និងដំណើរការរាល់ការងារ នៅមូលដ្ឋានជារៀងរាល់ថ្ងៃ (អភិបាល ខេត្ត/ក្រុង ស្រុក/ខណ្ឌ) និង
- ក្រុមអ្នកតំណាងមូលដ្ឋានដូចជាក្រុមប្រឹក្សារាជធានីខេត្តក្រុង ។ នេះគឺជាក្រុមអភិបាលដែល គេជ្រើសរើសឡើង ដោយផ្ទាល់ ដោយប្រយោល ឬដោយការចាត់តាំង ដោយរដ្ឋាភិបាលជាន់ខ្ពស់ ឬដោយតំណាងសហគមន៍ មាន ប្រភេទចំរុះនៃក្រុមអភិបាលនេះ ដែលខ្លះកើតឡើង ដោយការចាត់តាំង ។

### ខ)_ អ្វីទៅជាអភិបាលកិច្ចមូលដ្ឋាន?

អភិបាលកិច្ចមូលដ្ឋានមានស្ថាប័នមួយក្រុម យន្តការ និងដំណើរការ ដែលប្រជាពលរដ្ឋ និងក្រុមរបស់គេបានប្រើប្រាស់ ដើម្បីបង្ហាញពីផលប្រយោជន៍ និងតំរូវការរបស់គេ សម្របសម្រួលភាពចំរូងចំរាស់ រវាងគ្នា និងអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់គេ នៅថ្នាក់មូលដ្ឋាន។ ដំណើរការទាំងនេះផ្តោត សំខាន់ទៅលើសេចក្តីត្រូវការដែលលើក អំពីទំរង់ច្បាប់ និងអង្គភាពរដ្ឋបាលមូលដ្ឋាន។ ដំណើរការទាំងនេះរាប់បញ្ចូល ទាំងភាពចំរុះសំបូរបែប នៃទំនាក់ទំនងទាំងផ្លូវការ និងមិនផ្លូវការរវាងតួអង្គផ្សេងៗក្នុងការអភិវឌ្ឍ។ ឧទាហរណ៍ រដ្ឋបាលមូលដ្ឋាន វិស័យឯកជន សមាគម ស្ថាប័នដែលធ្វើវិសហមជ្ឈការ និងសង្គមស៊ីវិល ។ល។ ដែលជាអ្នកធ្វើឱ្យ

មានរូបរាង និងមានឥទ្ធិពលទៅលើលទ្ធផល និងប្រសិទ្ធភាពនៃប្រពន្ធ័នយោបាយ និងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ មូលដ្ឋានគ្រឹះនៃអភិបាលកិច្ចល្អមានច្រើនៈ ការចូលរួមរបស់ប្រជាពលរដ្ឋ ភាពជាដៃគូរបស់តួអង្គសំខាន់ៗ នៅថ្នាក់មូលដ្ឋាន សមត្ថភាពរបស់តួអង្គនៅគ្រប់ផ្នែក ចរន្តពត៌មានសំបូរបែប គណនេយ្យភាព នៃស្ថាប័ន និងការផ្តោតឆ្ពោះទៅរកអ្នកក្រីក្រ។

### គ)៱ ទំនាក់ទំនងអភិបាលកិច្ចល្អ នឹងអភិបាលកិច្ចមូលដ្ឋាន

| លរ | អភិបាលកិច្ចល្អ | អភិបាលកិច្ចមូលដ្ឋាន |
|---|---|---|
| ១ | ការចូលរួម | ប្រជាធិបតេយ្យភាវូបនីយកម្ម : វិមជ្ឈការអំណាចនយោបាយ |
| ២ | ការផ្តោតលើមតិឯកច្ឆ័ន្ទ | និន្នាការធ្វើឱ្យអ្នកមូលដ្ឋានសំរុះសំរួលគ្នាលើគំនិតខុសៗគ្នា |
| ៣ | គណនេយ្យភាព | គណនេយ្យភាពចំពោះប្រជាពលរដ្ឋ |
| ៤ | តម្លាភាព | មានទំនាក់ទំនងគ្នា និង ចរន្តពតិមានចំរុះ |
| ៥ | ការឆ្លើយតប | នៅជិតប្រជាពលរដ្ឋ និងតំរូវការរបស់គេ (ដឹងសុខទុក្ខ) |
| ៦ | ប្រសិទ្ធភាព និងប្រសិទ្ធផល | បើសិនមុខងារ ហិរញ្ញវត្ថុ និងមន្ត្រីសាធារណៈដែល មានសមត្ថភាព ត្រូវផ្តល់អំណាចឱ្យទាំងស្រុង |
| ៧ | សមធមិ | មានគោលនយោបាយគាំទ្រដល់ពលរដ្ឋក្រីក្រ |
| ៨ | នីតិរដ្ឋ (អនុវត្ត) | ក្របខ័ណ្ឌ ច្បាប់មូលដ្ឋានជាមួយវិមជ្ឈការ នយោបាយ |

## ៤. ក្របខ័ណ្ឌគោលនយោបាយអភិបាលកិច្ចនៅកម្ពុជា

### ៤.១. គោលនយោបាយគាំទ្រអភិបាលកិច្ចនៅកម្ពុជា




## ៤.២ គោលដៅអភិវឌ្ឍសហស្សវត្សរ៍

១. លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន

២. សំរេចគោលដៅនៃការអប់រំមូលដ្ឋាន ៩ ឆ្នាំជាសកល

៣. លើកកំពស់ឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រី និងផ្ដល់ភាពអង់អាចឱ្យស្រី

៤. កាត់បន្ថយអត្រាស្លាប់នៃកុមារ

៥. ពង្រឹងសុខភាពរបស់មាតា

៦. ការប្រយុទ្ធទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត

៧. ការធានាលើស្ថេរភាពបរិស្ថាន

៨. កសាងភាពជាដៃគូជាសាកលក្នុងការអភិវឌ្ឍ

គោលដៅអភិវឌ្ឍសហស្សវត្សរ៍របស់ប្រទេសកម្ពុជាមានបន្ថែមចំនុចទី ៩ គឺ : ការដោះមីន ច្បាប់បំបាត់គ្រឿងផ្ទុះ(UXO) និងកិច្ចសង្គ្រោះជនរងគ្រោះ ។

## ៤.៣ រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ

ផ្អែកតាមរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាចែកចេញជា រាជធានី និងខេត្ត។ រាជធានីចែកចេញជាខ័ណ្ឌ និងសង្កាត់ ។ ខេត្តចែកចេញជាក្រុង និងស្រុក។ ក្រុងចែកចេញជាសង្កាត់ ។ ស្រុកចែកចេញជាសង្កាត់ និងឃុំ ។ (រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនេះ នឹងពិពណ៌នាលំអិតក្នុងម៉ូឌុលទី ២ : ការអភិវឌ្ឍតាមបែបប្រជាធិប្បតេយ្យ)

## ចំណុចសំខាន់ដែលរៀនសូត្រ

១- អភិបាលកិច្ចល្អជា បេះដូងនៃយុទ្ធសាស្រ្តចតុកោណ